ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន
លេខ: ១៧១ សជណ.ប.ស្ក.កអធ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៥

# សេចក្តីណែនាំ

## ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការឈូសឆាយបង្គោលរបងចាប់យកដី ការកាប់ឆ្ការរុករានទន្ទ្រានយកដីព្រៃ ដុតព្រៃធម្មជាតិធ្វើចំការដាំដុះ ឈូសឆាយដីព្រៃ យកដីធ្វើជាកម្មសិទ្ធិនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ

ក្រសួងបរិស្ថានបានសង្កេតឃើញថា កន្លងមកភាពអនាធិបតេយ្យក្នុងការកាប់ឆ្ការរុករានទន្ទ្រានដីព្រៃ ការបោះបង្គោលរបងចាប់យកដី និងការដុតព្រៃធម្មជាតិធ្វើការដាំដុះ កាប់គាស់ ជីកកកាយយកដី ឈូសឆាយដីព្រៃ ឬធ្វើផ្លូវ និងសាងសង់សំណង់គ្រប់ប្រភេទ ព្រមទាំងធ្វើសកម្មភាពនានាខុសច្បាប់ផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ជាពិសេសនៅតាមតំបន់ព្រៃកន្ទិកសាប តំបន់ជាប់ព្រំប្រទល់កងនាវាចរ មូលដ្ឋានសមុទ្ររាម និងតំបន់ឆ្នេរសមុទ្ររាម ស្ថិតនៅក្នុងភូមិសាស្ត្រខណ្ឌព្រៃនប់ ក្រុងព្រះសីហនុបានកើតឡើងជាបន្តបន្ទាប់ ដោយគ្មានក្រែងរអែងដល់ការអនុវត្តន៍ច្បាប់ឡើយ។

អនុវត្តតាមបទបញ្ជា និងគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ពិសេសការអនុវត្តន៍ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាដែលនៅជាធរមាន រួមមាន:

- ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ។
- ព្រះរាជក្រមលេខ នស/រកម/១២៩៦.៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- ព្រះរាជក្រមលេខនស/រកម/០៨០១.១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល។
- ព្រះរាជក្រមលេខ នស/រកម/០៨០២.០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ។
- សេចក្តីប្រកាសលេខ ០១ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ។

- សេចក្តីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី។
- បទបញ្ជាលេខ ០១បប ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិនៅតាមបណ្តាខេត្ត ក្រុងមួយចំនួន។
- លិខិតលេខ ១០៧៤ សជណ.កស ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងគោលដៅធ្វើការគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ បាន ប្រកបដោយនិរន្តរភាពបរិស្ថានធម្មជាតិយូរអង្វែង សម្រាប់ជាកេរ្តិ៍ដំណែលដល់អនាគតកូនចៅ ចៅទួតជំនាន់ក្រោយ និងការពារគ្រោះធម្មជាតិដែលអាចកើតឡើងជាយថាហេតុ និងសម្រេចឱ្យបាននូវផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអណ្តត្តិទី៣នេះ ក្រសួងបរិស្ថានសូមធ្វើការណែនាំ និងជូនដំណឹងដល់បងប្អូន ឬជនទាំងឡាយដែលបាន និងកំពុងបោះបង្គោលរបងចាប់យកដី កាប់ឆ្ការរុករានទន្ទ្រានដីព្រៃ ដុតព្រៃធម្មជាតិធ្វើការដាំដុះ កាប់គាស់ ជីកកកាយយកដីឈូសឆាយដីព្រៃ ឬធ្វើផ្លូវ និងសាងសង់សំណង់គ្រប់ប្រភេទ ព្រមទាំងធ្វើសកម្មភាពនានាខុសច្បាប់ផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ក្នុងភូមិសាស្ត្រខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុទាំងមូល ត្រូវបញ្ឈប់សកម្មភាពខាងលើទាំងអស់ជាបន្ទាន់ ព្រមទាំងត្រូវប្រគល់ដីដែលបានកាប់ឆ្ការ រុករាន ឬឈូសឆាយទាំងអស់ ហើយមានកន្លែងខ្លះបានដាំដុះរួចហើយនោះ ក៏ត្រូវប្រគល់ជូនមកឱ្យឧទ្យានជាតិព្រះសីហនុ "រាម" វិញ ដើម្បីធ្វើការគ្រប់គ្រង ការពារជាសម្បត្តិសាធារណៈរបស់រដ្ឋ។

ក្នុងករណីដែលបងប្អូន ឬជនណាដែលចចេសរឹងទទឹងមិនព្រមបញ្ឈប់នូវរាល់សកម្មភាពឈូសឆាយ រុករាន កាប់ព្រៃធម្មជាតិ ដែលធ្វើឱ្យប៉ះពាល់ និងបំផ្លិចបំផ្លាញដល់ធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិខាងលើ ឬមិនអនុវត្តតាមគោលការណ៍ដូចខាងលើនេះទេ ក្រសួងបរិស្ថានសហការជាមួយអាជ្ញាធរដែនដី និងកម្លាំងសហការពាក់ព័ន្ធផ្សេងទៀត នឹងចាត់វិធានការចុះរុះរើ ព្រមទាំងរៀបចំសំណុំរឿងបទល្មើសបញ្ជូនទៅតុលាការ ដើម្បីចាត់ការទៅតាមផ្លូវច្បាប់ជាធរមាន។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក ម៉ារ៉េត
បណ្ឌិត.ពិភិទ្យា

<u>កន្លែងទទួល:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
- អភិបាលក្រុងព្រះសីហនុ
- មន្ទីរបរិស្ថានក្រុងព្រះសីហនុ
- ឯកសារ. កាលប្បវត្តិ